១ សេចក្តីក្នុងប្រយោគនេះ ហាក់ដូចជាមានបាត់សេចក្តីខ្លះច្រើនអន្លើ ទើបបាប់យកមិនបានជាក់ច្បាស់ ។ ពាក្យថា "ប្រាក់ពួក" ប្រហែលជាឈ្មោះមុខពន្ធអ្វីៗ ក្នុងសម័យនោះ ! ប្រយោគខាងដើមថា រីប្រាក់ពួកកុំឲ្យយកទៀយ "ឲ្យតែផ្តន្ទាដូចកំណត់" ប្រយោគខាងចុងត្រឡប់ជាមានសេចក្តីផ្ទុយថា ប្រាក់ពួកនោះកុំឲ្យលស់លាត្រាប្រណីទៀតហោង ដូច្នេះទើបឃើញថា ប្រហែលជាអ្នកចារ ១ ចម្លងរទ្ធងសេចក្តីចាស់របស់គេខ្ទេចខ្ទី ។ ២ វិជ្ជាមួយយ៉ាងដែលគាប់ភាក់ទងនៅនឹងខ្មោចបិសាច បើប្រុសហៅថា (ធ្មប់) ស្រីហៅថា (អាប) រកេតុអ្វីក្នុងសម័យនោះក៏ល្អផលធ្មប់នេះ ព្រាន់តែបេះកំឡួយកទៅកាប់សម្លាប់ចោល ! — មិនអាចដឹងបាន ។

ឲ្យឈរនោះ បើមានទ្រព្យរបស់ទៀសផងដោយនូវពាក្យសន្ទត បើឲ្យគេ
ពិបាកឲ្យសងកែទ្រព្យដើម បើរកទ្រព្យសងទៀតទេ ឲ្យកត់ជាសំបុត្រ
ហើយឲ្យនាំទៅដល់ចៅហ្វាយពល នូវព្រះស្នរភូមិ ឲ្យឡើងក្រាប
(បង្គំ) ទូលដល់ល្អងធូលីព្រះបាទ ហើយពុំចេះដឹងព្រះទ័យហោ ។ បើ
ពុំមានក្តីទេ ពុំដាច់ពុំជំពាក់ទ្រព្យគេនោះ ទោះអ្នកល្មើសទាំងព្រះបន្ទូល
ទោះសេព្រះបន្ទូល ត្រលើសព្រះបន្ទូលក្តី ប្រកួតប្រឆាំងព្រះរាជក្តី
បង្អាក់មហាត បណ្ណាមហាគក្តី ការមហាគយកទ្រព្យហ្លួងនូវសហ៊ប
សហ៊ុរក្តី ទោះកាត់សម្ដេចក្តី ទោះល្មើសនាហ្មឺនក្តី ទោះប្រកួតអ្នកអាង
គុះគិះដៀលពុំគោរពខ្លាចក្រឡាហោមនឹងនាហ្មឺនក្តី នូវកស្ត្រីជាគ្នាកឯង
ក្តី ទោះបង្អាក់បណ្ណាំរគក្តី រសាវពើរអស់ទាំងនេះ ទោះទោសកស្លាប់ឲ្យ
សម្លាប់ ធ៏ទោសកពុំដល់ស្លាប់ ទោះត្រូវក្រយោពិន័យប៉ុន្មានៗ ក៏ឲ្យ
សក់ពិន័យពលទៀត ឲ្យផ្តន្ទាក្តាលតាមដោយទោសធ្ងន់ស្រាល ឲ្យក
ពន៍កពាល កុំឲ្យកាបពាយឆាយទៀត ។ ឯទោសពលបើខុសទាំងព្រះ
បាទអ្នកជាអម្ចាស់ផែនអស់ព្រះគង្គផង បើល្មមសម្លាប់ធ្វើដោយព្រះត្រាស្ប
ដឹងសម្លាប់នោះ បើល្មមត្រូវក្រយោពិន័យ ទោះប្រើនឲ្យបាញ់សណ្ដោក
កាប់ក្បាលផង ឲ្យគង់ជាពលដូចដែលហោង ។

# គោរម្យងារនិងស័ក្តិមន្ត្រីស្រុកក្រៅ

ឧកញ៉ាតេជោ ជាចៅហ្វាយស្រុកសន្ទុកស័ក្តិ ១០ ហ៊ុពាន់ឯកជាខ្លួនកោះ(១) ។ ឧកញ៉ាពិស្ណុលោក ចៅហ្វាយស្រុកប្រាំងស្តាំ មានចៅមឿង ៣ មឿង ។ ឧកញ៉ាអាជួន ចៅហ្វាយស្រុកត្បូងឃ្មុំស្តាំ មានចៅមឿង ៤ មឿង ។ ឧកញ៉ាសួគ៌ាលោក ចៅហ្វាយស្រុកពោធិ៍សាត់ធ្វេង មានចៅមឿង ៤ មឿង ។ ឧកញ៉ាធម្មតេជោ ចៅហ្វាយស្រុកបាភ្នំ (ធ្វេង) មានចៅមឿង ៦ មឿង ។ អស់ចៅហ្វាយស្រុកទាំង ៤ នេះ សឹងជាជើងគ្រួស(២) ស័ក្តិ ១០ ហ៊ុពាន់ឯក ។

ឈ្មោះឧកញ៉ានគរ(៣) ដើមខ្សែ ស័ក្តិ ៩ ហ៊ុពាន់ មានចៅមឿង ៥ មឿង ។ ឧកញ៉ាឧទ័យធិរាជ ស្នាខ្សែ ស័ក្តិ ៩ ហ៊ុពាន់ ចៅហ្វាយស្រុកសំរោងទង មានចៅមឿង ៣ មឿង ។ ឧកញ៉ាសេនាធិបតីចៅហ្វាយស្រុកព្រះត្រពាំង(៤) ស័ក្តិ ៩ ហ៊ុពាន់ មានចៅមឿង ១០ មឿង ។

---

១ ខ្លួនកោះ ក្នុងទីនេះជាពាក្យសំគាល់ដល់មន្ត្រីជាន់ខ្ពស់បំផុតសម្រាប់ខេត្តក្រៅ ។

២ ជើងគ្រួស ប្រហែលជាក្លាយមកពីពាក្យថា ជើងគ្រឹះទេដឹង ព្រោះពាក្យនេះប្រែថា "ជើងផ្ទះ, ជំហរផ្ទះ" ។ មន្ត្រីជាន់ខ្ពស់ទាំង ៤ នេះជាអ្នកសម្រេចរាជការខេត្តក្រៅ មានតំណែងដូចជាមន្ត្រីធំ ៗ ក្នុងដែលហៅថា "ចតុស្តម្ភ" ប្រែថាសសរ ៤ ជាជំនឹងអធិបតី គឺ អគ្គមហាសេនាបតី ជាអ្នកសម្រេចរាជការទឹកដីជាមួយនឹងមហាក្សត្រទ្រង់រាជ្យ ។ ៣ ប្រហែលជាសំដៅយកនគរវត្ត - នគរធំ នៅក្នុងទីរួមខេត្តសៀមរាបសព្វថ្ងៃនេះ ។ បើមិនដូច្នេះទេ គង់សំដៅយកអង្គរបុរីនៅក្នុងខេត្តតាកែវ ។ ៤ ខេត្តព្រះត្រពាំង សព្វថ្ងៃនៅក្នុងដែនកូសាំងស៊ីន ។

ទំកញ្ញាធម្មាធិបតី ទៅហៅយ(ស្រកសម្បូរ សក្តិ ៩ ហ៊ូពាន់ មាន
ទៅមឿង ៣ ទៀង ។
ពញាធរាវង្សាស្នាខ្មែរ ទៅហៅយ ((ស្រក) បាទី សក្តិ ៨ ហ៊ូពាន់
មានទៅមឿង ៤ ទៀង ។ ពញាមហាតេជ ទៅហៅយ(ស្រក(ស្រីសុខ
ស្នាខ្មែរឯស្នា សក្តិ ៨ ហ៊ូពាន់ មានទៅមឿង ៤ ទៀង ។
ទៅពញាកជាសុត ទៅហៅយ(ស្រកបាភ្នំ សក្តិ ៨ ហ៊ូពាន់ មាន
ទៅមឿង ២ ទៀង ។ ទៅពញាកជាកិមត្ត ទៅហៅយ(ស្រកគោក
សេះ មានទៅមឿង ៣ ទៀង ។ បទៅហៅយ ទាំង ២ នេះសក្តិ ៨
ហ៊ូពាន់ដូចគ្នា ។
ទៅពញាកជាស្នេហា ទៅហៅយ(ស្រកភ្នំពេញ សក្តិ ៨ ហ៊ូពាន់
មានទៅមឿង ៣ ទៀង ។ ទៅពញាយោធាធិបតីកជ ទៅហៅយ(ស្រក)
បាទីយមាស សក្តិ ៨ ហ៊ូពាន់ មានទៅមឿង ៦ ទៀង (ស្រក
ទាំង ២ នេះសក្តិដូចគ្នា ។
ទៅពញាអនុរាជ ទៅហៅយ(ស្រកស្រុកស្រីសោភ័ណ
ហ៊ូពាន់ មានទៅមឿង ៣ ទៀង ។ ទៅពញាសេនាធិបតី ទៅហៅយ
(ស្រកក្រគរ សក្តិ ៨ ហ៊ូពាន់ មានទៅមឿង ៤ ទៀង ។
[illegible] ទៅហៅយ(ស្រកសំបុក សក្តិ ៨ ហ៊ូពាន់ មាន
ទៅមឿង ១ ទៀង ។ (ព្រះសុរិន្ទធិបតី ទៅហៅយ(ស្រក(ព្រៃក្របាស

សក្តិ ៦ ហ៊ុពាន់ មានចៅមឿង ២ ទៀត ។ ព្រះសិរីសោភ័ណ ចៅហ្វាយស្រុកព្រៃវែង សក្តិ ៦ ហ៊ុពាន់ មានចៅមឿង ៣ ទៀត ។ ព្រះយសតេជោ ចៅហ្វាយស្រុករលាប្អៀរ សក្តិ ៦ ហ៊ុពាន់ មានចៅមឿង ២ ទៀត ។ ព្រះយោធាធិបតី ចៅហ្វាយស្រុកកំពង់សោម សក្តិ ៦ ហ៊ុពាន់ មានចៅមឿង ២ ទៀត ។ ព្រះកជតេជោ ចៅហ្វាយស្រុកព្រៃក្តី សក្តិ ៦ ហ៊ុពាន់ ........[១] ។ ចៅហ្វាយស្រុកទាំង ៩ នេះខាងស្តាំ[២] ។

ព្រះសេនាសង្គ្រាម ចៅហ្វាយស្រុកក្រគរ សក្តិ ៦ ហ៊ុពាន់ មានចៅមឿង ១ ទៀត ។ ព្រះមនោសង្គ្រាម ចៅហ្វាយស្រុកក្រង សក្តិ ៦ ហ៊ុពាន់ មានចៅមឿង ២ ទៀត ។ ព្រះយោធាសង្គ្រាម ចៅហ្វាយស្រុកទ្រង សក្តិ ៦ ហ៊ុពាន់ មានចៅមឿង ១ ទៀត ។ ព្រះជ័យតេជោ ចៅហ្វាយស្រុកជើងព្រៃ សក្តិ ៦ ហ៊ុពាន់ មានចៅមឿង ៤ ទៀត ។ ព្រះអធិកតេជោ ចៅហ្វាយស្រុកបាជ័យ[៣] សក្តិ ៦ ហ៊ុពាន់ មានចៅមឿង ៣ ទៀត ។ ព្រះកមតេជោ ចៅហ្វាយ

---

១ មានចៅមឿងប៉ុន្មានទៀតមិនប្រាកដ ។ ២ មិនគ្រប់ ៩ បើរាប់រួមទាំងពីចៅពញាក្នុងសេចក្តីមកឃើញតែ ៨ ជាក់ ។ តាមរំលងនេះគួរតែ ៨ ស្រុកទេមិនមែន ៩ ឡើយ ព្រោះចៅហ្វាយស្រុកខាងឆ្វេងមាន ៨ ដែរ ។ ៣ ពាក្យជ័យនេះប្រហែលសំដៅយកពាក្យជាអារ្យ នៅក្នុងទីរួមខេត្តកំពង់ចាមសព្វថ្ងៃនេះ ។

ស្រុកស្ទឹងត្រង់ស័ក្តិ ៦ ហ៊ូពាន់ មានចៅមឿង ២ ទៀង ។ ព្រះពុទ្ធក្រៃ ចៅហ្វាយស្រុកផ្ទល ស័ក្តិ ៦ ហ៊ូពាន់ មានចៅមឿង ១ ទៀង ។ ព្រះមនោសង្គ្រាម(១) ចៅហ្វាយស្រុកស្វាយទាប ស័ក្តិ ៦ ហ៊ូពាន់ មានចៅមឿង ១ ទៀង ។ អស់ចៅហ្វាយស្រុកទាំង ៧(២) នេះមានចេង ។

## ស័ក្តិមន្ត្រីក្រោមបង្គាប់ចៅហ្វាយស្រុក

ឯចៅហ្វាយស្រុកស័ក្តិ ១០ ហ៊ូពាន់នេះ ផ្ទប់ស៊ីងឈ្មោះអកខុន ស័ក្តិ ៨ ហ៊ូពាន់ យោកប្រែ ក្រឡាបញ្ជី សុភា ស៊ីងឈ្មោះជាអគបាន ស័ក្តិ ៤ ហ៊ូពាន់ ជម្ពាតិតទ្វៃក្រប ។ ស៊ីងឈ្មោះជាអគពាន់ស័ក្តិ ២ ហ៊ូពាន់ ។ ចៅមឿង ស៊ីងឈ្មោះជាអគហ្មឺនស័ក្តិ ៤ ហ៊ូពាន់ ផ្ទប់ចៅមឿង ស៊ីងឈ្មោះអកពាន់ស័ក្តិ ២ ហ៊ូពាន់ ក្រឡាបញ្ជីសម្រាប់ចៅមឿង ស៊ីងឈ្មោះគគហ្មឺនស័ក្តិ ១ ហ៊ូពាន់ ។ ចៅបានស័ក្តិ ២ ហ៊ូពាន់ ផ្ទប់ចៅបានឈ្មោះអកហ្មឺនស័ក្តិ ១ ហ៊ូពាន់ ក្រឡាបញ្ជីសម្រាប់ចៅបាន ឈ្មោះចៅហ្មឺនស័ក្តិ ១ ហ៊ូពាន់ ចាស់ស្រុកឈ្មោះចៅហ្មឺន (វៃវ)

---

១ គោរម្យងារៈមនោសង្គ្រាមនេះដូចគ្នានឹងគោរម្យងារចៅហ្វាយស្រុកក្នុងខាងលើនេះ ចៅហ្វាយស្រុកទាំងពីរស្រុកនេះ ប្រហែលមានគោរម្យងារដៀងគ្នាទេ តែអ្នកចម្លងមកខុសទេដឹង? ។ ២ តាមរៀងពិតត្រូវតែ ៨ ទេ ព្រោះចំនួនចៅហ្វាយស្រុកខាងស្ដាំ ស័ក្តិ ៦ ហ៊ូពាន់ មាន ៨ នាក់ ចៅហ្វាយស្រុកឆ្វេងក៏ត្រូវតែមានចំនួន ៨ នាក់ដែរ មិនមែនជា ៧ ដូចចំនួនខ្ញុំបូករួមនោះឡើយ ។

ស័ក្តិ ៧ ហ៊ូពាន់ ។ ចំណែកពលទេពក្តី នាយឃោសក្តី នាយសុភាក្តី នាយសន្ទ្រការក្តី សួស្តិ៍ក្រក្តី អស់កម្លោះសព្វពួកនេះក្តី អស់នាយតាំង ៥ នេះ ឈ្មោះចៅហ្វាយស័ក្តិ ១ ហ៊ូពាន់ អស់តាំងនេះសឹងទៀតចៅហ្វាយស្រុក ។

ឯចៅហ្វាយស្រុកស័ក្តិ ៤ ហ៊ូពាន់ក្តី ចៅហ្វាយស្រុកស័ក្តិ ៥ ហ៊ូពាន់ក្តី ជំទប់(១) សឹងឈ្មោះអកហ្មឺនស័ក្តិ ៦ ហ៊ូពាន់ ។ យោកក្បាត់ ក្រឡាបញ្ជី សូភា(២) សឹងឈ្មោះអកពាន់ ស័ក្តិ ៤ ហ៊ូពាន់ ។ ធម្មាពិករ ក្រឡាបញ្ជី សឹងឈ្មោះអកហ្លួង ស័ក្តិ ៤ ហ៊ូពាន់ ។ ចៅមឿងសឹងឈ្មោះចៅមឿង ស័ក្តិ ៤ ហ៊ូពាន់ ជំទប់ចៅមឿងឈ្មោះអកហ្លួង ស័ក្តិត្រឹង(៣) ។ ក្រឡាបញ្ជីសម្រាប់ចៅមឿងឈ្មោះចៅហ្លួង ស័ក្តិ ១ ហ៊ូពាន់ ។ ចៅបានឈ្មោះចៅបាន ស័ក្តិ ២ ហ៊ូពាន់ ជំទប់ចៅបានឈ្មោះចៅហ្លួងស័ក្តិត្រឹង ។

---

១ ជំទប់ៈ ក្នុងសម័យសព្វថ្ងៃមិនប្រើឲ្យជាជំទប់ខេត្ត, ចំណែកឯសម័យបុរាណទេ មានតែជំទប់ឃុំមាន ៣ ថ្នាក់ ជំទប់លេខ ១ ហៅថាជំទប់ភេជា, លេខ ២ ជំទប់សេនា, លេខ ៣ ជំទប់ភក្តី ។ ស្តាប់មើលគោរម្យងារជំទប់ គួរតែជាអ្នកមានយសស័ក្តិខ្ពង់ខ្ពស់គ្រាន់បើដែរ តែគួរការជំទប់ផ្លាស់មកជាចៅឡាត់ស្រុក, ក្លាយខេត្តទៅវិញ ជាអធិការស័ក្តិជំទប់ធ្លាក់មកនៅត្រឹមបំផុតតែជំទប់ឃុំ ។ ២ សូភាៈ ជាមន្ត្រីខាងក្រសួងតុលាការ ក្នុងសម័យសព្វថ្ងៃនេះត្រឡប់បានឡើងយសស័ក្តិខ្ពង់ខ្ពស់ស្មើនឹងចៅហ្វាយស្រុក - ខេត្តប៉ែកខាងរដ្ឋបាល ។ ៣ ពាក្យថាៈ “ ត្រឹង ” ប្រហែលជាពាក្យថៃទេដែលប្រែថា “ កន្ទះ, ពាក់កណ្តាល ” បានសេចក្តីថាអកហ្លួងមានសក្តិត្រឹមពាក់កណ្តាលរបស់ឡឿង ។

ចាស់ស្រុកឈ្មោះចៅហ្ញុនស័ក្តិ ១ ហ៊ូពាន់ ចម្បើនពលទេពក្តី នាយឃោយក្តី នាយស្ទូកាក្តី នាយសង្ឃការក្តី ស្មួក្រៅក្តី អស់ចម្លោះសព្វផ្ទុកក្តី នាយតាំង ៥ នេះ សឹងឈ្មោះចៅហ្ញុនស័ក្តិ ១ ហ៊ូពាន់ អស់តាំងនេះ សឹងឡើងចៅហ្វាយស្រុក ។

ឯចៅហ្វាយស្រុកស័ក្តិ ៧ ហ៊ូពាន់ក្តី ស័ក្តិ ៦ ហ៊ូពាន់ក្តី ជំទប់សឹងឈ្មោះជាអគពាន់ ស័ក្តិត្រឹមចៅហ្វាយ (ស្រុក) ។ យោកបត់ ក្រឡា-បញ្ជីសឹងឈ្មោះជាអគហ្ញុន ស័ក្តិ ២ ហ៊ូពាន់ ។ ធម្មាធិករក្រឡាបញ្ជី សឹងឈ្មោះជាចៅហ្ញុនស័ក្តិ ១ ហ៊ូពាន់ ។ ចៅមឿនឈ្មោះជាអគហ្មឺន ស័ក្តិ ២ ហ៊ូពាន់ ជំទប់ចៅមឿនឈ្មោះជាចៅមឿន ស័ក្តិត្រឹមចៅមឿន ។ ក្រឡាបញ្ជីសម្រាប់ចៅមឿនឈ្មោះជាចម្បើន សឹងស័ក្តិ ១ ហ៊ូពាន់ ។ ចៅបានឈ្មោះជាចៅបាន ស័ក្តិ ១ ហ៊ូពាន់ ជំទប់ចៅបានឈ្មោះជាចៅហ្ញុនស័ក្តិត្រឹម ។

ចាស់ស្រុកឈ្មោះជាចៅហ្ញុនស័ក្តិ ១ ហ៊ូពាន់ ចម្បើនពលទេពក្តី នាយឃោយក្តី នាយសុភាក្តី នាយសង្ឃការក្តី ស្មួក្រៅក្តី ចម្បើនអស់ចម្លោះសព្វផ្ទុកក្តី អស់នាយតាំង ៥ នេះ សឹងឈ្មោះជាចៅហ្ញុនស័ក្តិ ១

ហ៊ុតាន់ អស់តាំងនេះសឹងឡើងចៅហ្វាយស្រុក (១) (នេះសារស្នាច្បាប់ក្រម ចៅហ្វាយស្រុក អ្នកកញ្ញាធិកដវេជ្ជា ដើមឈ្មោះពេជ្រ (តាបមូន) ។ ហ៊ុនដិក

ចប់ច្បាប់ក្រមចៅហ្វាយស្រុកពីបុរាណតែប៉ុណ្ណេះ

---

* តាមទំនងនេះឃើញថា ចៅហ្វាយស្រុកមានអំណាចនឹងសក្តិយសខ្ពង់ខ្ពស់បំផុត នៅក្នុងខេត្តក្នុងស្រុករបស់ខ្លួន មិនដូចសម័យសព្វថ្ងៃនេះទេ ដែលមានការបែងចែកអំណាចនឹងមុខក្រសួងដាច់ដោយឡែកពីគ្នា ដូចជា ផ្នែកខាងតុលាការ, វេជ្ជបាល, សាសនា, ការសិក្សា ពឹងមានមុខក្រសួងនឹងអំណាចដាច់ដោយឡែកៗ ពីគ្នា ។ ក្នុងសម័យនោះទុកជាមានមុខក្រសួងដាច់ដោយឡែកពីគ្នាដែរ តែត្រូវឡើងទៅលើចៅហ្វាយស្រុកទាំងអស់ ។ ដូច្នេះទើបឃើញថា ចៅហ្វាយស្រុកជាន់នោះ ជាអ្នកសម្រេចកិច្ចការស្ទើរតែដាច់ស្រេចដោយខ្លួនឯងទាំងអស់ ទាំងផ្នែកខាងអាណាចក្រ ទាំងផ្នែកខាងពុទ្ធចក្រដែលនៅក្នុងស្រុករបស់ខ្លួន ។

## វិធីរាប់ថ្ងៃ - ខែ - ឆ្នាំ - រដូវ

ព្រះគ្រូញាណសំវរ ញាណ - ឈឿន រៀបរៀងនិងផ្ដុំបទ

### លេខថ្ងៃ (ពាក្យ ៧)

លេខ ១ លោកកំណត់ទុកថា　ជាថ្ងៃអាទិត្យជាក់ស្ពាន់
លេខ ២ លោកប្រាប់ឲ្យប្រកាន់　ទុកជាថ្ងៃចន្ទប្រាកដនៅ ។
លេខ ៣ លោកឲ្យស្គាល់ពាក្យពារ　ជាថ្ងៃអង្គារសេទតហៅ
លេខ ៤ លោកប្រាប់កុំសៅហ្មៅ　ចំណាំទុកនៅជាថ្ងៃពុធ ។
លេខ ៥ លោកត្រាទុកឥតខាស　ជាថ្ងៃព្រហស្បតិ៍ចាំឲ្យមុត
លេខ ៦ លោកស្ដីចំហុត　ជាថ្ងៃសុក្រសុខឥតឃ្លាតឃ្លា ។
ឯលេខ ៧ លោកសំណៅ　ទុកជាថ្ងៃសៅរ៍ចប់តក
បូករួមទាំងអស់លោកប្រាប់ថា　ជាមួយសប្តាហៈគប់គ្រាន់ ។
លេខនៃឈ្មោះថ្ងៃទាំងនេះ　បាត្រូវចេះកុំពុញព្រាន់
ដើម្បីនឹងប្រើតាមជំនាន់　ដែលប្រព្រឹត្តទាន់កាលសម័យ ។
ដូចសំបុត្រផ្ទះហោរារឿងណា　ដែលយើងត្រូវត្រាទុកឈ្មោះថ្ងៃ
និងឈ្មោះខែឆ្នាំត្រូវតែលៃ　យកលេខនោះនៃប្រើសុទ្ធសាធ ។
ផ្សេងសរសេរពាក្យថាថ្ងៃ　បន្ទាប់ត្រូវលៃគួរសមតាម (១)

---

(១) ធ្វើនៅថ្ងៃ ១ ៤+១ ឆ្នាំរកាសប្តស័ក ព. ស. ២៤៧៧ (ខាងកើត) ។
ធ្វើនៅថ្ងៃ ២ ៤+៣ ឆ្នាំរកាសប្តស័ក ព. ស. ២៤៧៧ (ខាងលោក) ។

ឲ្យយ៉ាងពិសេសល្អសមស្អាត  នាងទ្រូងតាតបាចចុះលេងថ្ងៃ ។
លើក្រោមតាកបាចប្រាប់លេងប័ក្ស  ខ្ញីត្រនោចជាក់សារសោរដៃ
បើជានាងខ្ញីគលិខិតថៃ  ចុះលេងលើនែតាតបាចនោះ ។
បើជាចំណែកត្រនោចវិញ  ក្រាលេះក្រោមមិញតាកបាចស្មោះ
នាងស្កាំតាកបាចឲ្យចុះបោះ  សំគាល់សេងឈ្មោះនៃត្រូវប្រើ ។
គទៅលោតឲ្យដាក់ឈ្មោះឆ្នាំ  សកកជប្រែចាំត្រូវចុះធ្វើ
នៅចុងបំផុតកុំរះរើ  ដើម្បីស្រួលប្រែក្នុងសំបុត្រ ។
នេះជារបៀបបោកណា  លោតបានថែងតាយ៉ោងចំហុត
ខុតសម្រាប់កម្ពុជបុត្រ  ប្រែស្រួលបំផុតបំប្រួញខ្លី ។

(របស់លោក អៀង-ហ៊ុង)

## លេខខែ

មិគសិរលេខ ១ ពុំព្រួយគិត    គលេខ ២ ពិតខែបុស្ស
ខែមាឃលេខ ៣ ឥតកង្វា.    ផល្គុនមាសា ត្រាលេខ ៤;
ខែចេត្របួលផ្កាតាមកំណត់    លេខ ៥ ប្រាកដនៅទីនិទ្ទួន
វិសាខលេខ ៦ ត្រូវសមសួន    ៧ ក្នុងក្បួនជួនខែជេស្ឋ;
អាសាឍចំណួលបួលវស្សា    បើលេខអស្តាបាត្រូវប៉ះ
គឺលេខ ៨ នោះឯងនេះ    ខែស្រាពណ៍គះនេះលេខ ៩;
លេខ ១០ ជាប់ជាខែភទ្របទ    ប្រាកដបើត្រាកត់តែតាមក្បួន
រដូវផ្កាកបិណ្ឌបុណ្យចាំមួន    ជុំខែរចិនយួនថៃដាប់ខែ;
អស្សុជ ១១ ចាត្រូវចាំ    ចំណាំទុកនៅកុំភ្លេចភ្លេ
កត្តិក ១២ ជាចុងគេ    ជួបចប់ជាខែ ១២ គត់;
លេខថ្ងៃលេខខែពីរបែបនេះ    កុមារត្រូវប៉ះចាំឲ្យស្ទាត់.
ចំរៀនចេះឆ្ញេញឲ្យគ្មានបទ    ទុកប្រើសំប្រុតកត់បញ្ជី ។

## ខែពេញ—ខាត

ខែជប់ពីរតាមធម្មតា    សិងមិនដូចគ្នាទេណាពៅ.
ខែខ្លះមានថ្ងៃចំរូណាទៅ    សាមសិបខ្ទង់នៅមិនមានខ្វះ ។

ខែខ្វះមានថ្ងៃម្ភៃប្រាំបួន　　ចំនួននោះឯងជាខែខ្វះ
ប៉ុណ្ណេះណា កខែគជាយ៉ាងច្បាស់　　ចំនួនខែខ្វះប្រាំមួយខែ ៗ
ទីមួយដំបូងគឺមិគសិរ　　ជាគម្រប់ពីរមាឃមាសា
ផល់គម្រប់បីខែចេត្រា　　ផកបជេស្ឋាគម្រប់បួន ៗ
ទាល់តែខែស្រាពណ៍គ្រប់ជាប្រាំ　　អស្សុជផុតចាំឲ្យថែមជូន
ប្រាំមួយខែនេះថ្ងៃម្ភៃប្រាំបួន　　ប្រាំដូចោលជួនៗជាខែខ្វះ ៗ
ចំណែកខែគត់នោះវិញណា　　ប្រាំមួយមាសាគឺដូច្នេះ
កត្តិកជាមុនគេឯងនេះ　　តជាប់ពីនេះគឺខែបុស្ស ៗ
ផល្គុណវិសាខអាសាឍ្ហ　　ភទ្របទាក្រោយបង្អស់
ប្រាំមួយខែទៀតគត់លើសលស់　　អស់ខែទាំងនោះ ៣០ ថ្ងៃ ៗ
ឯខែដែលខ្វះនោះឯងគួរ　　កុមារផងគ្រប់កុំសង្ស័យ
ខ្វះទាំងនោះបកលស់សម័យ　　ខាងខ្នើតវិស័យឥតមានខ្វះ ៗ
ក្នុងខែមួយៗមានបក្សពីរ　　ខាងកេសរកឲ្យជាក់ច្បាស់
បក្សមួយព្រះពន្លឺស្រឡះ　　ហោលតាមពាក្យចាស់ហៅថាខ្នើតៗ
បក្សមួយព្រះពន្លឺថយស្ដើ　　អាប់ខ្ទូនកសិមិនឆាយឆើត
ខុសគ្នានឹងកាលនៅខាងខ្នើត　　ទើបបានជាគេហៅរនោច ៗ
ឆ្នាំមួយមានខែដប់ពីរគត់　　នៅនឹងកំណត់មិនខានគួប
ជួនណាលើកខែមួយឲ្យជួប　　ប៉ុណ្ណេះស្រេចស្រាបខែអាសាឍ ៗ

ឆ្នាំនោះមានខែថែមថ្មី លើសឆ្នាំជាថ្មីដោយបង់ឃ្លាត

លោកនិយមប្រើសំនួនជាតិ សមតាមក្បួនខ្នាតបញ្ចប់ហោរ[១] ។

## វិធីរាប់ឆ្នាំ

## ឧកញ៉ាសុត្តន្តប្រីជា (ឥន្ទ)

វិធីរាប់ឆ្នាំតាំងច្បាប់ ទាំងតែរដណ្ដប់នោះណាទៅ

ឆ្នាំជូតកណ្ដុរជាដើមទៅ ឆ្នាំឆ្លូវនាមគោសក៏ពេជ ។

ឆ្នាំខាលនាមខ្លាខ្លាំងឥតមោះ ឆ្នាំថោះទន្សាយសមរូបលាជ

ឆ្នាំរោងរោងនាមនាគពេជ ម្សាញ់ឯងតាមនាមពស់វែង ។

មមីបានទីប្រាំពីរគត់ សេះតាមនាមសេះជាសត្វឯក

មមែពពែឥតមានប្លែក ឆ្នាំវកអតិរេកនាមវានរ ។

គរកកប់មកឆ្នាំរកា សញ្ញានាមមាន់ថែបរ

ឆ្នាំចសុនខនាមករណ៍ គឺសុនខក្ដែជង្ហា ។

ឆ្នាំកុរនាមជ្រូកលោកបញ្ចប់ ចាំគិតរដណ្ដប់ដោយគណនា

ហៅពួកកុមារទាំងអស់គ្នា ចូរចាំសព្វហ័ណាក្មេងអើយ ។

---

១ បើលើកខែអាសាឍពីរដងប្រើយ៉ាងនេះ គឺបឋមាសាឍៈ ថ្ងៃ + ៨ ឆ្នាំ... ។ ទុតិយាសាឍៈ ថ្ងៃ + ៨ ឆ្នាំ... ។

# វេជ្ជទាំង ៣

កូនចៅមួយៗវេជ្ជថៃ ណាកុមារកុមារា
ឯវេជ្ជបីតែងចប់ចាំ មួយហោមន្តពេលនោះ ។
គ្រាក្ដៅលោកហៅថាគិម្ហន្ត លុះភ្លៀងជោរផង់សេព្វនា
វេជ្ជមួយមានថៃធាតុខបត្ត ចាំងចប់ដូចគ្នាជាដប់ពីរ ។
មួយទៀតកត្តិកធ្លាក់ផល្គុន ត្រជាក់លើសលន់នៅសព្វទី
ពេលនោះហៅឈ្មោះតាមបុរាណ សាទៀមជាកផង់ហេមន្តា ។
វេជ្ជទីពីរជំណានោះ សឹងបួនខែស្មោះតៗគ្នា
មួយពេលផល្គុនដកបគ្រា អាសាឍមាសាពេញបូណ៌មី ។
វេជ្ជនោះឯងលោកជាំទមុន ហៅថាគិម្ហន្តព្រោះក្ដៅផង
គ្មីពេលបរនាវិញទី ជាវេជ្ជថ្ងៃសេព្វនា ។
បើដឹងមានថ្ងៃបួនខួបកំណត់ កត្តិកចប់ចុងបុនវស្សា
ក្រែមថ្ងៃពេញបូណ៌មីស៊ាំរឹក ជួបជុំគ្នាវិញជាពប ។
ហៅកើយហៅខ្ចាំឲ្យចប់ ធាតុពុញចប់បាតសភាព
ទំនងពេលនេះតជាប តេញជាពាក្យគាព្យអ្នកប្រាជ្ញមុន ។
លេខថ្ងៃខែឆ្នាំចាំឲ្យស្ទាត់ កុំឲ្យភ្លាំងភ្លាត់ទុកជាធន
ទាំងវេជ្ជបីកុំភ័ន្ត ក្រៃនឹកឲ្យទាន់ផងបងអើយ ។

(ចប់)

យុនសុវត្ថិវង្ស យូ-អ៊ុន រៀបរៀង

(តទៅ)

## លក្ខណៈ, រស, បច្ចុបដ្ឋាន, បទដ្ឋានរបស់មិច្ឆាទិដ្ឋិ

មិច្ឆាទិដ្ឋិនេះ មានអ្វីជាលក្ខណៈ អ្វីជារស (កិច្ច) អ្វីជាបច្ចុបដ្ឋាន (សេចក្តីប្រាកដឬផល) អ្វីជាបទដ្ឋាន (អាសន្នហេតុឬទីទៃ)? ។

មិច្ឆាទិដ្ឋិនេះ មានការកាន់ខុសដោយគ្មានឧបាយមិនប្រាជ្ញាជាលក្ខណៈ, មានកិច្ចរវល់តែការរក្សាប្រកាន់ស្អិតតាមគំនិតដែលខ្លួនយល់ឃើញខុសជាកិច្ច, មានការជំពប់ចិត្តបំពោះទៅរកខុសជាផល; ធម៌ ៣ យ៉ាងគឺ ភាពជាអ្នកមិនប្រាថ្នាឲ្យចួបប្រទះនឹងអ្នកមានសីលមានធម៌សប្បុរស ១ ភាពជាអ្នកមិនប្រាថ្នានឹងស្តាប់ធម៌របស់សប្បុរស ១ ភាពជាអ្នកកំណាញ់ទ្រព្យមិនមានសទ្ធាជ្រះថ្លាក្នុងព្រះរតនត្រ័យ ១ ទាំង ៣ នេះជាបទដ្ឋានគឺជាអាសន្នហេតុឬទីទៃរបស់មិច្ឆាទិដ្ឋិ ព្រោះមិច្ឆាទិដ្ឋិនេះកាលបើមានធម៌ទាំង ៣ នេះ ទើបកើតឡើង ឬ តាំងនៅបាន បើមិនមានទេ ក៏តាំងនៅមិនបានវិញ, ប្រៀបដូចក្រាលការល្អិតទាំងឡាយដែលតាំងនៅបានព្រោះអាស្រ័យផែនដីជាទីទ្រទ្រង់ឯង (១) ។ មែនពិត មិច្ឆាទិដ្ឋិរមែងមានធម៌ទាំង ៣ ប្រការ មានភាពជាអ្នកមិនប្រាថ្នាឲ្យចួបនឹងពួកសប្បុរសជាដើមនោះឯងជាកម្លាំង ដើម្បីទប់ទល់ឲ្យរឹងជាប់នៅជាមិច្ឆាទិដ្ឋិ

១ សេចក្តីដែលសំដែងមកនេះ ដកយកក្នុងគម្ពីរវិសុទ្ធិមគ្គភាគ ៣ ត្រង់ទន្ទឹមទ្វេស ។

ដកចេញ, ដូចសញ្ជ័យបរិព្វាជក, កាលដែលឧបតិស្សនិងកោលិតបរិ-ព្វាជកជាបរិស័ទខ្លួន ចូលមកអញ្ជើញឲ្យចូលទៅគាល់ព្រះសម្ពុទ្ធឯវេឡុវ័ន. មិនព្រមទៅសោះ ត្រឡប់ជាសួរថា "ក្នុងលោកនេះ មនុស្សល្ងង់និងមនុស្សជាអ្នកប្រាជ្ញណាច្រើនជាងណា?" បរិព្វាជកទាំង ២ នាក់តបថា "មនុស្សល្ងង់ច្រើន, ឯអ្នកប្រាជ្ញតិចពេកណាស់" សញ្ជ័យបរិព្វាជកពោលថា "បើដូច្នោះខ្ញុំយកតែខាងច្រើន, ជនទាំងឡាយល្ងង់ៗចូលមកក្នុងសំណាក់ខ្ញុំ ជនទាំងឡាយជាអ្នកប្រាជ្ញៗចូលទៅរកព្រះសម្ពុទ្ធចុះ" ។ មួយទៀតដូចកាលមិគារសេដ្ឋីដែលជាពុកក្មេកនាងវិសាខា, សូម្បីព្រះសម្ពុទ្ធទ្រង់យាងចូលដល់ក្នុងផ្ទះខ្លួនហើយ ក៏មិនពេញមកអង្គុយជិត ស្តាប់ធម៌របស់ព្រះអង្គដោយចូលចិត្តឡើយ ។ រឿងនេះមានសំដែងរឿងមិគារ-សេដ្ឋីនោះ ទុកក្នុងរឿងនេះដោយសង្ខេប ស្រង់យកចំពោះតែសេចក្តីដែលទាក់ទងនឹងប្រយោជន៍នេះមកពណ៌នា ដើម្បីជាគ្រឿងប្រដាប់ប្រាជ្ញនៃសាធុជនដូចសេចក្តីតទៅនេះ ៖

## រឿងមិគារសេដ្ឋី (១)

សេចក្តីដំណាលថា នាងវិសាខាជាធីតារបស់ធនញ្ជយសេដ្ឋី និងនាងសុមនទេវីនៅក្នុងក្រុងសាកេត ក្នុងដែនអង្គៈ បានទៅជាភរិយារបស់បុណ្ណវឌ្ឍនកុមារ ដែលជាកូននៃមិគារសេដ្ឋី ក្នុងក្រុងសាវត្ថី ។ មិគារ-

១ រឿងនេះនៅក្នុងរឿងវិសាខាក្នុងគម្ពីរធម្មបទដ្ឋកថាភាគ ៣ ត្រង់បុប្ផវគ្គ ។

សេដ្ឋីកាលធ្វើអាវាហមង្គលឲ្យបុណ្ណវឌ្ឍនៈ ដណ្ដឹងនាងវិសាខាកូនស្រីសាកេតរួចហើយ ក៏នាំនាងវិសាខាមកកាន់ផ្ទះរបស់ខ្លួនឯងក្រុងសាវត្ថី បានអញ្ជើញពួកអចេលកៈទាំង ៥ រយ នាក់មកជប់លៀង ហើយផ្ញើដំណឹងទៅឲ្យនាងវិសាខាថា "ចូរនាងមកថ្វាយបង្គំព្រះអរហន្ត" ។ នាងវិសាខាស្មានថាជាព្រះអរហន្តមែន លុះមកដល់ឃើញសុទ្ធតែជាអ្នកអាក្រាតកាយ ក៏បន្ទោសសេដ្ឋីរួចចូលទៅឯលំនៅរបស់ខ្លួនវិញ ។ ពួកអចេលកៈឃើញដូច្នោះ ក៏បន្ទោសសេដ្ឋីថា "អ្នករកស្រីដទៃមិនបានឬ? បានជាទៅយកស្រីមហាកាឡកណ្ណីជាសាវិការបស់សមណគោតមមកឲ្យចូលផ្ទះនេះ សូមអ្នកបណ្ដេញវាឲ្យដើរចេញអំពីផ្ទះនេះទៅ" សេដ្ឋីមិនហ៊ានដេញ ត្រឡប់ជាប្រាប់ទៅវិញថា "លោកម្ចាស់គ្រប់អង្គ ចូរនៅស្ងៀមសិនចុះ" ។ ក្រោយពីនោះមក សេដ្ឋីក៏កំពុងតែបរិភោគក្រយាហារក្នុងពេលព្រឹក មានព្រះថេរៈ ១ រូបនិមន្តចូលទៅបិណ្ឌបាត សេដ្ឋីឃើញហើយតែធ្វើជាមិនឃើញ បែរអង្គុយឈោកបរិភោគតែម្យ៉ាង ចួនជាវេលានោះនាងវិសាខាក៏កំពុងតែអង្គុយបក់ឲ្យសេដ្ឋី ទ្រាំអត់នៅស្ងៀមមិនបានទើបទូលព្រះថេរៈថា "សូមលោកម្ចាស់និមន្តទៅប្រោសសត្វខាងមុខចុះ ដ្បិតឪពុកក្មេកខ្ញុំព្រះករុណា លោកតែស៊ីតែអាហារចាស់[1] ទេ" ។ ក្នុងដំណើរនេះពួកនិគន្ថបានញុះសេដ្ឋីឲ្យបណ្ដេញនាងចេញអំពីផ្ទះម្ដងទៀត តែសេដ្ឋីទ្រាំអត់បាន ។ សំដីនាង

១ សំដៅដល់កុសលបុណ្យដែលធ្វើទុកពីជាតិមុន ។

វិសាខាដែលស្ដីឲ្យឪពុកក្មេកជាទី២លើកនេះ បណ្ដាលឲ្យឪពុកក្មេកទៅប្ដឹងផ្ដល់ដល់កុដុម្ពិក:ទាំង ៨ នាក់(១) ឲ្យជំនុំជំរះ តែចាប់ទោសនាងវិសាខាមិនបានក៏ត្រឡប់ជាសុំខមាទោសនឹងនាងវិញ ព្រមទាំងឲ្យគេបើកឱកាសឲ្យនាងវិសាខានិមន្ដព្រះសម្មាសម្ពុទ្ធមកធ្វើបុណ្យធ្វើទានក្នុងផ្ទះតាមចិត្ត ។ នាងវិសាខាគាល់បានគាប់ហើយក៏ប្រើប្រាស់ឲ្យទៅនិមន្តព្រះទសពលមក ក្នុងវេលាព្រឹកមួយ ។ ចំណែកពួកសមណ:អាក្រាតកាយ ល្ប:ឮថាព្រះសម្ពុទ្ធនិមន្តមកផ្ទះសេដ្ឋី ក៏នាំគ្នាទៅអង្គុយចាំព័ទ្ធជុំវិញផ្ទះ ។ នាងវិសាខាបាត់ផ្ចិតផ្ចង់គ្រឿងសក្ការ:ចាត់ពួកជាមួយព្រះទសពលរួចហើយ ជូនដំណឹងទៅអញ្ជើញឪពុកក្មេកថា "សូមលោកឪពុកអញ្ជើញមកអង្គាសបង្ហាញប្រោះព្រះសាស្ដា" ។ សេដ្ឋីមានប្រាថ្នានឹងមកតាមពាក្យកូនប្រសាស្រី តែពួកអាជីវកយាគកមិនឲ្យមកទេ បង្វែរដំណាក់តបទៅវិញថា "ប្អូនកូនស្រីនាងអង្គាសខ្លួនឯងចុះទៅចុះ" ។ នាងវិសាខាអង្គាសខ្លួនឯង សុះរួចស្រេចកត្តកិច្ចហើយ បានឲ្យដំណឹងទៅម្ដងទៀតថា "សូមលោកឪពុកអញ្ជើញមកស្ដាប់ធម៌" ។ គ្រានោះសេដ្ឋីក្រោកដើរចេញពីលំទៅ ប្រឹងមិនទៅស្ដាប់ធម៌ ពួកអចេលកបានឃាត់ថា "បើអញ្ជើញទៅស្ដាប់ក៏អញ្ជើញចុះ ប៉ុន្តែត្រូវអង្គុយខាងក្រៅរនាំង ។ វេលានោះ ព្រះសាស្ដាទ្រង់តាំងផ្ដើមអនុបុព្វីកថា សំដែងធម៌ឲ្យជួបជា

---

១ កាលធនញ្ជយសេដ្ឋីបញ្ជូនកូនស្រី ... កុដុម្ពិក: ៨ នេះ រើលការខុសត្រូវកូនស្រីដំនួសខ្លួន ។

គេចាប់អង្រួនដើមព្រឹក្សធំផង ទ្រង់ឲ្យផាយហារមេឃបង្អុរចុះឡើងភ្លៀងពីតមក-ផងដែរ ។ កាលព្រះសាស្ដាកំពុងសំដែងធម៌ត្រឡប់មានជំណើរនៅឡើងនៅខាងមុខមិនដាច់ មិគារសេដ្ឋីក៏លោតែដំកល់ស៊ប់ក្នុងសោតាបត្តិផលដ៏ប្រដាប់ដោយន័យ ១ ពាន់ ជាអ្នកមិនសង្ស័យក្នុងព្រះត្រ័យរតន៍ ទើបបើកជាយកំពន់មកផ្ទាល់ដោះនាងវិសាខា ហើយទុកនាងជាមាតា ។ តាំងដើមអំពីថ្ងៃនោះមក គេហៅនាងវិសាខាថា មិគារមាតា ។ មិគារសេដ្ឋីលុះលែងបៀតដោះនាងវិសាខាហើយ នៅក្រាបទៀបព្រះបាទព្រះសម្ពុទ្ធ ហើយប្រឹបព្រះបាទាដោយដៃផង ថ្នក់ព្រះបាទាដោយមាត់ផង រួចប្រកាសឈ្មោះខ្លួនថ្វាយព្រះទសពលថា " ខ្ញុំព្រះអង្គឈ្មោះមិគារសេដ្ឋី " ក្រាបទូលថា " ព្រះអង្គ ! ខ្ញុំព្រះអង្គមិនដឹងថាធ្វើទានក្នុងក្រុមព្រះអង្គបានផលប្រពៃថ្លៃពេះទេ, ទើបតែវេលានេះបានដឹង ព្រោះអាស្រ័យកូនប្រសាស្រី, ខ្ញុំជាបុគ្គលរួចចាកអបាយទុក្ខទាំងពួងហើយ, កូនប្រសាស្រីដែលមកកាន់ផ្ទះខ្ញុំនេះ ឈ្មោះថាយកទាំងសេចក្ដីចំរើន យកទាំងប្រយោជន៍ យកទាំងសេចក្ដីសុខមកឲ្យខ្ញុំផង ។

សោហំ អជ្ជ បជានាមិ យត្ថ ទិន្នំ មហប្ផលំ
អត្ថាយ វត មេ ភទ្ទា សុណិសា ឃរមាគតា

ទេយ្យទានដែលគេថ្វាយក្នុងសាសនាឯណា ជាទានមានផលច្រើន,

ខ្ញុំព្រះអង្គទើបនឹងដឹងច្បាស់នូវសាសនានោះក្នុងថ្ងៃនេះ, កូនប្រុសស្រី និងចៅប្រុសស្រីញាតិ មកកាន់ផ្ទះខ្ញុំនឹងឲ្យសេចក្ដីជំរាបដល់ខ្ញុំព្រះអង្គ ។

## លើករឿងធៀបនឹងធម៌

រឿងដែលដំណាលមកនេះ សាធុជនគប្បីប្រៀបថា ត្រង់មិគារ-សេដ្ឋីឃាត់នាងវិសាខាមិនឲ្យនិមន្តព្រះសម្មាសម្ពុទ្ធ ពួកអចេលកៈញុះសេដ្ឋីឲ្យបណ្ដេញនាងវិសាខាអំពីផ្ទះចេញក្ដី នេះត្រូវត្រង់បទដ្ឋានទី ១ គឺភាពជាអ្នកមិនចង់ជួបនឹងពួកសប្បុរស, ត្រង់ពួកអចេលកៈឃាត់មិនឲ្យសេដ្ឋីស្ដាប់ធម៌ នេះត្រូវត្រង់បទដ្ឋានទី ២ គឺភាពជាអ្នកមិនចង់ស្ដាប់ធម៌ពួកសប្បុរស, ត្រង់សេដ្ឋីមិនបានយកបាយទៅដាក់បាត្រព្រះថេរៈ១រូប ដែលនិមន្តចូលមកបិណ្ឌបាត នេះត្រូវត្រង់បទដ្ឋានទី ៣ គឺភាពជាអ្នកកំណាញ់ទ្រព្យមិនមានសទ្ធាក្នុងព្រះរតនត្រ័យ ។

## កំណើតមិច្ឆាទិដ្ឋិ

មិច្ឆាទិដ្ឋិ កើតឡើងដោយហេតុប៉ុន្មានយ៉ាង? គឺអ្វីខ្លះ? ។ មិច្ឆាទិដ្ឋិ កើតឡើងដោយហេតុ ២[១] យ៉ាង គឺ:

---

១ ស្រង់ពីគម្ពីរ ទុកនិបាត, អង្គុត្តរនិកាយ ផលេ ទ្វេ ភិក្ខវេ ទ្វេ បច្ចយា មិច្ឆាទិដ្ឋិយា ឧប្បាទាយ "ម្នាលភិក្ខុទាំងឡាយបច្ច័យ ២ ប្រការនេះឯងឲ្យមិច្ឆាទិដ្ឋិកើតឡើងបាន" ។

៣- បរតោ ឃោសោ ស្តាប់អសទ្ធម្មកថាអំពីបុគ្គលដទៃ

២- អយោនិសោមនសិការោ មិនធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា

## អធិប្បាយ

១- ស្តាប់អសទ្ធម្មកថា អំពីបុគ្គលដទៃ, ពាក្យថា អសទ្ធម្មកថា ប្រែថា "កថាជាអសទ្ធម្ម គឺពាក្យមិនមែនធម៌គាថរបស់ពួកសប្បុរស, ពាក្យថា "បុគ្គលដទៃ" ក្នុងទីនេះ សំដៅយកពួកមនុស្សអសប្បុរស ដែលជាអ្នកនិយាយអសទ្ធម្មកថា ៗ មែនពិត មនុស្សអសប្បុរសរមែងមិននិយាយធម៌គាថដែលមានខ្លឹមសារផ្ដល់ខ្លួនដល់បុគ្គលដទៃទេ និយាយតែពាក្យដែលនាំឲ្យខូចប្រយោជន៍ក្នុងលោកនេះ និងលោកខាងមុខ គឺ តែងនិយាយដឹកនាំពួកជនមិនឲ្យជឿកម្មនិងផលរបស់កម្ម, មិនឲ្យជឿហេតុដែលគួរជឿ, មិនឲ្យខ្លាចបាបមិនឲ្យខ្ពើមអំពើទុច្ចរិត, មិនឲ្យកក់ស្មុកខ្លាចបាប មិនឲ្យរអាចិត្តចំពោះអំពើទុច្ចរិត, មិនឲ្យខំស្វាហាប់រៀនសូត្រ, មិនឲ្យមានសេចក្ដីព្យាយាមក្នុងកុសលធម៌, មិនឲ្យមានស្មារតីសេចក្ដីរឭកត្រូវ មិនឲ្យមានប្រាជ្ញាការពិចារណាក្នុងផ្លូវលោកផ្លូវធម៌ និយាយដឹកនាំពួកជនឲ្យមានតែមានៈសេចក្ដីប្រាថ្នាច្រើន, មិនឲ្យមានសន្តោសតាមមានតាមបាន, មិនឲ្យស្ងាត់កាយស្ងាត់ចិត្ត, មិនឲ្យរក្សាសីល ជាដើម ។ **(តទៅ)**

និក្ខេបបរិយាយ

ព្រះគ្រូមហាបញ្ញា ឆាយ-ស៊ិន ក្រុមជំនុំព្រះត្រៃបិដក

រៀបរៀង

ឧបត្ថ សុគតស្ស

មាតាបេត្តិកំ ជន្តុំ ការុលោដ្ឋាបថាយិនំ
សណ្ហំ សចិលសម្ពាសំ មេត្តុណោយ្យព្យាបាយិនំ
មច្ចេវិធយេ យុត្តំ សព្វំ គោចាកិកុំ ធរំ
តំ វេ នេភ តាវត្ថិសា អាបាតុ សព្ឫវេសោ ឥតិៗ

សម្តេចព្រះភគវាព្រះអង្គជាសាស្តាឯកនៃសត្វលោក ទ្រង់ប្រកបដោយមហាករុណាចំពោះពួកវេនេយ្យសត្វ មានព្រះប្រាជ្ញាទីពឹងបម្រុងប្រជានិករឲ្យបានផលត្រៃយោគកែសេចក្តីសុខសន្តាន្ត តាមគួរដល់ឋានឧបនិស្ស័យដែលខ្លួនបានប្រព្រឹត្តទៅ ដោយទេសនាបរិយាយមានប្រការជាអនេក ៗ ការទេសនាប្រដៅវេនេយ្យសត្វជាកិច្ចដែលព្រះអង្គបានបំពេញគ្រប់៤៥ ព្រះវស្សា តាំងអំពីកាលត្រាស់ដឹងបរមាភិសេកសម្មាសម្ពោធិញ្ញាណហូតមកដល់អវសានកាលនៃបរិនិព្វានសម័យ ទ្រង់មានព្រះហឫទ័យដ៏ពេញទៅដោយមហាករុណា ដែលជាហេតុមិនឲ្យព្រះអង្គធុញទ្រាន់ ក្នុងការខ្វាយខ្វល់រៀនប្រដៅពួកសត្វដែលកិលេសរួបរឹតមន្ទិលចិត្តនៅតែវង្វេងទៅតាមធម្មតា មូលធម៌ដែលព្រះអង្គសំដែងទុកមកនោះមាន

១- បរតោ ឃោសោ ស្តាប់អសទ្ធម្មកថាអំពីបុគ្គលដទៃ

២- អយោនិសោ មនសិការោ មិនធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា

## អធិប្បាយ

១- ស្តាប់អសទ្ធម្មកថា អំពីបុគ្គលដទៃ, ពាក្យថា អសទ្ធម្មកថា ប្រែថា "កថាជាអសទ្ធម្ម គឺពាក្យមិនមែនធម៌ពោធិរបស់ពួកសប្បុរស, ពាក្យថា "បុគ្គលដទៃ" ក្នុងទីនេះ សំដៅយកពួកមនុស្សអសប្បុរស ដែលជាអ្នកនិយាយអសទ្ធម្មកថា ។ មែនពិត មនុស្សអសប្បុរសរមែងមិននិយាយធម៌ពោធិដែលមានខ្លឹមសារដល់ខ្លួនអំពីបុគ្គលដទៃទេ និយាយតែពាក្យដែលនាំឲ្យខូចប្រយោជន៍ក្នុងលោកនេះ និងលោកខាងមុខ គឺ តែងនិយាយដឹកនាំពួកជនមិនឲ្យជឿកម្មនិងផលរបស់កម្ម, មិនឲ្យជឿហេតុដែលគួរជឿ, មិនឲ្យខ្លាចបាបមិនឲ្យខ្ពើមអំពើទុច្ចរិត, មិនឲ្យកក់ស្លុតខ្លាចបាប មិនឲ្យគោរពចិត្តចំពោះអំពើសុចរិត, មិនឲ្យខំស្វាហាប់រៀនសូត្រ, មិនឲ្យមានសេចក្តីព្យាយាមក្នុងកុសលធម៌, មិនឲ្យមានស្មារតីសេចក្តីរឭកត្រូវ មិនឲ្យមានប្រាជ្ញាការដឹងសព្វក្នុងលោកុត្តរធម៌ និយាយដឹកនាំពួកជនឲ្យមានតែមានសេចក្តីប្រាថ្នាច្រើន, មិនឲ្យមានសន្តោសតាមមានតាមបាន, មិនឲ្យស្ងាត់កាយស្ងាត់ចិត្ត, មិនឲ្យរក្សាសីល ជាដើម ។ (តទៅ)

## សេចក្តីបរិយាយ

ព្រះគ្រូមហាបទុម មាឃ ស៊ុន ក្រុមជំនុំព្រះត្រៃបិដក

រៀបរៀង

### ជយត្តុ សុគតស្ស

មាតាបេត្តិភរំ ជន្តុំ　　កុលេជេដ្ឋាបចាយិនំ
សណ្ហំ សខិលសម្ភាសំ　បេសុណេយ្យប្បហាយិនំ
មច្ឆេរវិនយេ យុត្តំ　　សច្ចំ កោធាភិភុំ នរំ
តំ វេ ទេវា តាវតិំសា　អាហុ សប្បុរិសោ ឥតិ ៗ

សម្តេចព្រះភគវាព្រះអង្គជាសាស្តាឯកនៃសត្វលោក ទ្រង់ប្រកបដោយមហាករុណាចំពោះពួកវេនេយ្យសត្វ មានប្រាថ្នានឹងចម្លងប្រជានិករឲ្យបានផុតពីក្រយ ពោលគឺសេចក្តីសុខសម្រាន្ត តាមគួរដល់ឧបនិស្ស័យដែលនឹងប្រព្រឹត្តទៅ ដោយទេសនាបរិយាយមានប្រការជាអនេក ៗ ការទេសនាប្រោសវេនេយ្យសត្វជាកិច្ចដែលព្រះអង្គបានបំពេញគ្រប់ ៤៥ ព្រះវស្សា តាំងអំពីកាលត្រាស់ដឹងបរមាភិសេកសម្មាសម្ពោធិញ្ញាណ រហូតមកដល់អវសានកាលនៃបរិនិព្វានសម័យ ទ្រង់មានព្រះហឫទ័យពេញទៅដោយមហាករុណា ដែលជាហេតុមិនឲ្យព្រះអង្គធុញទ្រាន់ ក្នុងការទូន្មានប្រៀនប្រដៅពួកសត្វដែលកិលេសរួបរឹតមន្ទិលឲ្យរលស់ទៅតាមកម្មៈមូលដ្ឋានដែលព្រះអង្គសំដែងទុកមកនោះមាន

ខំរៀបចំតែងប្រព្រឹត្តទៅតាមការប្រែប្រួលរបស់សត្វ ទាំងកាលសម័យ ព្រះធម៌ទេសនាដែលព្រះអង្គទ្រង់សំដែងហើយ អ្នកមានប្រាជ្ញាគប្បីឃើញ បានថាជាសុភាសិតធម៌ទាំងជានិយ្យានិកធម៌ពិត ។ អ្នកដែលបានស្ដាប់ ហើយក៏រមែងអនុវត្តទៅតាមហេតុ ដែលនាំមកនូវប្រយោជន៍ដ៏ធំទូលាយ គោលគឺប្រយោជន៍បច្ចុប្បន្ន, ប្រយោជន៍ក្នុងបរលោក និងប្រយោជន៍យ៉ាងឧត្តម គឺព្រះនិព្វានដែលជាឯកន្តបរមសុខ; ក្នុងទីនេះ សូមលើកយកបរិយាយអនុសាសនីពាក្យប្រដៅនៃព្រះបរមសាស្ដាចារ្យ ដែលមាននាមថា ឥន្ទវត្ត [1] ដើម្បីជាប្រយោជន៍ដល់ពុទ្ធមាមកបុគ្គលទាំងឡាយ ក្នុងការញុំាងធម្មប្បដិបត្តិដែលនៅមិនទាន់កើតឲ្យកើតឡើងបាន ខំញុំាងធម្មប្បដិបត្តិដែលកើតមានហើយឲ្យរឹតតែបរិបូណ៌ចំរើនកើនឡើងទៀត; ឥន្ទវត្តនោះមាន ៧ ប្រការ គប្បីជ្រាបតាមន័យដែលរៀបរៀងជាគោលឧទ្ទេសបទដោយលំដាប់ដូចតទៅនេះ :

## ១ – មាតាបេត្តិភរណៈ [2]

''ការចិញ្ចឹមមាតាបិតា,,

សូមរៀបរាប់អំពីពាក្យថា មាតាបិតាជាមុនសិន: ស្រីអ្នកញុំាងបុត្រឲ្យកើតឈ្មោះថា ជននី, បុរសអ្នកញុំាងបុត្រឲ្យកើតឈ្មោះថា ជនកៈ;

---

១ ក្នុងច្បាប់ខ្លះលោកឲ្យឈ្មោះថា វត្តបទ ក៏មាន ។ ២ ក្នុងគាថាដែលលើកយកពោលទុកខាងដើម លោកសំដែងតែ មាតុបដ្ឋាន, ប៉ុន្តែសូមដាក់សម្រួលទៅជាមាតាបិតុបដ្ឋានវិញ គ្រប់មាតិកាតទៅ ដើម្បីស្រួលការអធិប្បាយ ។

ជននីនិងជនកៈ ទាំងពីរនេះហៅថាមាតាបិតា ជាអ្នកទ្រទ្រង់គុណដ៏ធំ កូនចៅបុត្តធីតា: ពួកជនដែលបានអត្តភាពមកក្នុងលោក ឈ្មោះថាមាន មាតាបិតាជាដែនកើត ដោយហេតុថា: ជាអ្នកឲ្យកំណើតគឺជីវិត, រីមែង បរិភោគលោហិតនៃមាតាតាំងពីអំពីកាលចុះចាប់បដិសន្ធិ ទាំងអាហារ: ដែលចំរើនឡើងក៏ត្រូវអាស្រ័យបាចណាមនៃមាតា ហេតុដល់វេលា ដែលប្រសូតចេញចាកគភ៌: គឺ:ដែលមាតាត្រូវបំរុងថ្នាក់ថ្នមដោយការ ជំលួនោះ គឺមាតាបន្ទុះចេញនូវលោហិតដ៏សថ្លាជាអាហារបរិភោគទាំង យប់ទាំងថ្ងៃពុំមានស្រាកស្រាន្ត, តែងចាំថែទាំព្យាបាលគ្រប់សារិយាបថ ទាំង ៤ ឲ្យបានប្រព្រឹត្តទៅស្រួលដោយសេចក្ដីសុខក្សេមក្សាន្ត, ដរាប ទាល់តែបុត្តធីតានោះមានវ័យចំរើនធំឡើង ឆ្លងផុតកាលទំនុកបំរុងជាទិច្ច ការដែលមាតាទទួលភារៈដ៏ធ្ងន់យ៉ាងនេះ ក៏ព្រោះទឹកចិត្តរបស់លោក ប្រកបដោយសេចក្ដីស្រឡាញ់ មិនអាចនឹងកាត់ចិត្តឲ្យដាច់ស្រឡះ ឬ នឹងលះបង់បាន ។ ចំណែកបិតាសោត កាលមាតាធ្វើសេចក្ដីបរិហារ អស់កាលយូរដូច្នេះហើយ ក៏ត្រូវតាំងចិត្តទទួលភារៈដ៏ធ្ងន់ដូចគ្នា គឺត្រូវ ស្វែងរកគ្រឿងបរិភោគ និងទ្រព្យសម្បត្តិមកជាគ្រឿងចាត់ចែង ដើម្បី ឧបត្ថម្ភបំរុងដល់មាតានិងបុត្តធីតាឲ្យបានទទួលសេចក្ដីសុខ, យកចិត្តឈឺ ឆ្អាលរក្សាកិច្ចការផ្សេងៗ . រាំងសេចក្ដីភ័យចាប់អន្តរាយទាំងខាងក្នុងនិង ខាងក្រៅមិនឲ្យមាតាកាសអព្យាស្រ័យ ដើម្បីនឹងបានធ្វើកិច្ចបរិហារបុត្ត

ធីតាដោយល្អ ទាំងនេះក៏ព្រោះសេចក្ដីស្រឡាញ់បុត្តធីតាជាចំណែកដ៏ដូច
គ្នា  ហេតុនេះមាតាបិតាទើបឈ្មោះថាជាអ្នកមានឧបការដ៏ធំ  ទំនើរកវត្ថុ
ឯណាមកប្រៀបផ្ទឹមពុំបាន  ព្រោះត្រូវថែរក្សាបីបាច់តាំងតែពីកាលនៅក្នុង
គភ៌រហូតប្រសូតចេញមកពីគភ៌ ក៏នៅតែបំរុងរក្សាទៀតដរាបដល់តែបុត្តធី-
តាតាំងគ្រងខ្លួន ដោយស្របការពារក្នុងផ្ទះសម្បែងបាន ។ កំឡាំងកាយ
កំឡាំងទ្រព្យនិងកំឡាំងនិងចិត្តរបស់ខ្លួន  ទៅវិញប៉ុណ្ណឹងខំទុកបំរុងបានគ្រប់ព្រម
ណាក៏ចេះតែស្ដាយទៅបុត្តធីតាទាំងអស់ត្រឹមណោះ ៗ បើពោលចំពោះ
គុណធម៌ដែលជាចំណែកនាទីរបស់មាតាបិតាគប្បីធ្វើទុកបំរុងដល់បុត្តធីតា
នោះ លោកពោលទុកដោយសង្ខេបត្រឹម ៥ ស្ថានគឺ ១- បាបា និវារេន្តិ
រមែងហាមឃាត់មិនឲ្យធ្វើសេចក្ដីអាក្រក់ ឯបុត្តធីតាដែលល្អរមែងមិន
ធ្វើឲ្យមាតាបិតាលំបាកចិត្តព្រោះខ្លួន  តែរក្សាខ្លួននៅក្នុងទំនងរបស់មាតា
បិតា ២- កល្យាណេ និវេសេន្តិ រមែងញ៉ាំងបុត្តធីតាឲ្យតាំងនៅក្នុងកម្ម
ដែលបណ្ឌិតជនគប្បីកាន់យកពោលគឺអំពើឯណាដែលប្រព្រឹត្តទៅ  ដើម្បី
សេចក្ដីល្អប្រពៃ  ដែលនឹងនាំមកនូវសេចក្ដីសុខចំរើនព្រមទាំងប្រយោជន៍
ដល់បុត្តធីតានឹងវង្សត្រកូល,  រមែងដឹកនាំប្រៀនប្រដៅបុត្តធីតាក្នុងអំពើ
ដ៏ប្រពៃ  ដែលជាផ្លូវនាំឲ្យបុត្តធីតាបានទៅជាអ្នកមានអធ្យាស្រ័យសុចរិត
ល្អ ជាសិរីនៃត្រកូល គឺកេរ្តិ៍ឈ្មោះល្បោះសំឡេងជាទីពេញចិត្តរបស់អ្នកដទៃ;
៣- សិប្បំ សិក្ខាបេន្តិ  រមែងញ៉ាំងបុត្តធីតាឲ្យសិក្សាសិល្បវិទ្យា

តំកូនបីបាច់ថែរក្សាយ៉ាងសមគួរនិងថែរក្សាសេចក្ដីបេះដូងហើយ មាតាបិតា បង្ហាត់បុត្រធីតាឲ្យស្គាល់ការរៀនសិក្សាដោយខ្លួនឯង ឬដោយការនាំចូលទៅកាន់ពេលរៀន ហើយផ្ញើទុកដាក់នឹងគ្រូបាធ្យាយដែលមានសេចក្ដីបេះដូង ដើម្បីឲ្យបង្ហាត់បុត្រធីតា ឲ្យបានទៅជាអ្នកចេះដឹងក្នុងវិជ្ជាសាស្ត្រផ្សេងៗទៀត ដែលជាផ្លូវដឹកនាំបុត្រធីតាឲ្យចិញ្ចឹមជីវិតបានដោយងាយក្នុងអនាគតកាល ៤– បដិរូបេន ទារេន សំយោជេន្តិ រមែងប្រកបផ្សំផ្គុំបុត្រធីតាដោយភរិយាស្វាមីដ៏សមគួរ គឺបុត្រធីតាចំរើនវ័យមានអាយុសមគួរល្មមឲ្យមានភរិយាស្វាមីគ្រប់គ្រាន់ជាគ្រួសារបានហើយ ទើបជានាទីរបស់មាតាបិតាដែលនឹងជួយបុត្រធីតារបស់ខ្លួន ដោយការស្វែងរកភរិយាស្វាមីជាគូរនាដ៏សំខាន់ ចំណែកមួយសម្រាប់អ្នកនោះគ្រប់គ្រងគេហ-ដ្ឋាន កិច្ចនេះជាភារៈរបស់មាតាបិតាអ្នកប្រាថ្នាសេចក្ដីល្អ រមែងតែងតាំងថែរក្សាឲ្យមានសមគួរដល់វ័យ, សេចក្ដីបេះដូង, សេចក្ដីអង់អាច, សេចក្ដីប្រព្រឹត្តល្អនិងការងារស្វែងរកទ្រព្យចិញ្ចឹមជីវិត, ដែលល្មមនឹងចិញ្ចឹមគ្នាបាន ហើយអាចនឹងតាំងខ្លួនឲ្យរឹងប៉ឹងបានតទៅ ៥– សមយេ ទាយជ្ជំ និយ្យាទេន្តិ រមែងប្រគល់ទ្រព្យមត៌កឲ្យបុត្រធីតាក្នុងសម័យដ៏គួរនិងវេលាយកទៅគ្រប់គ្រង ពោលគឺក្នុងកាលដែលបុត្រធីតាមានភរិយាស្វាមីគ្រប់គ្រងគេហដ្ឋានដោយខ្លួនឯងហើយ សម្រាប់ជាដើមទុនក្នុងការស្វែងរកផលប្រយោជន៍ចិញ្ចឹមជីវិតតទៅ ។

(មានត)

# ពាក្យសួររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរនៅក្រសួងពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ត្រូវការអ្នកចេះភ្លេងបារមី ( ព្រះបរមី ) និងចំនុកច្រៀងភ្លេងនេះដែលជាភ្លេងប្រគំក្នុងពិធីឡើងអ្នកតាស្ដេច ព្រមទាំងភ្លេងឯទៀតនិងចំនុកច្រៀងដែលសម្រាប់ប្រគំក្នុងពេលឡើងអ្នកតាទូទៅ ។

បើអស់លោក-អ្នកមើលសៀវភៅកម្ពុជសុរិយា ស្គាល់អ្នកណាចេះភ្លេងទាំងនេះយ៉ាងស្ទាត់ សូមបង្ហាញឈ្មោះនិងទីលំនៅអ្នកនោះដល់ក្រុមជំនុំ ឬក៏ឲ្យអ្នកនោះចូលទៅជួបនឹងក្រុមជំនុំ, កាលបើបញ្ជាក់ឃើញថាបានការពេញចិត្តក្រុមជំនុំហើយ, ក្រុមជំនុំនឹងជូនរង្វាន់ពុំខាន ។